## នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
## នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | **អង់គ្លេស** |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 27-Aug-2012, 15:31
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "សំណើរបស់ នួន ជា អនុលោមតាមវិធាន៣៥ សុំឲ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងនឹង ហោ ណាំហុង"

---

| អ្នកដាក់ឯកសារ: | អ្នកទទួលឯកសារ: | ចម្លងជូន: |
|---|---|---|
| **សហព្រះរាជអាជ្ញា:** | **អង្គជំនុំជម្រះសាលាដំបូង:** | **ជនជាប់ចោទ:** |
| លោកស្រី ជា លាង | ចៅក្រម និល ណុន, ប្រធាន | នួន ជា |
| លោក Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | អៀង សារី |
| | ចៅក្រម យ៉ា សុខន | ខៀវ សំផន |
| | ចៅក្រមJean-Marc LAVERGNE | |
| | ចៅក្រម យូ ឧត្តរា | **មេធាវីការពារក្ដីជនជាប់ចោទ:** |
| | | លោក សុន អរុណ |
| | **សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:** | លោក Michiel PESTMAN |
| | | លោក Victor Koppe |
| | ពេជ អង្គ | លោក អាង ឧត្តម |
| | Elisabeth SIMONNEAU FORT | លោក Michael G.KARNAVAS |
| | | លោក គង់ សំអុន |

Anta GUISSE
លោក Arthur VERCKEN
លោក Jacques VERGÈS

## I. សេចក្តីផ្តើម និង ប្រវត្តិនីតិវិធី

១- នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១២ មេធាវីការពារក្តី នួន ជា ("មេធាវីការពារក្តី") បានស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង ចាត់ការជាបន្ទាន់ប្រឆាំងនឹង ហោ ណាំហុង តាមវិធាន៣៥ នៃវិធានផ្ទៃក្នុង ("សំណើ")[1]។ មេធាវីការពារក្តីតវ៉ាថា"ចំណាត់ការជាបន្ទាន់"[2] គឺជាការសមស្របដោយហេតុថា "ចំណាប់អារម្មណ៍ថ្មីៗនៅក្នុងសារព័ត៌មានរបស់ ហោ ណាំហុង ដែលគេត្រូវតែមើលឃើញថា ជាការប៉ុនប៉ងដាក់ឥទ្ធិពលមិនត្រឹមត្រូវទៅលើអង្គជំនុំជម្រះសាលាដំបូង សាក្សីដែលនឹងចូលមកបំភ្លឺខាងមុខ មេធាវីការពារក្តី ព្រមទាំងសាធារណជនជាទូទៅ មានតម្លៃស្មើនឹងការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាល នៅ អ.វ.ត.ក"[3]។ មេធាវីការពារក្តីស្នើថា "ចំណាត់ការជាបន្ទាន់ មានទម្រង់ដូចជាការស្តីបន្ទោស ជាសាធារណៈដល់រដ្ឋមន្ត្រីការបរទេស និងការព្រមានជាផ្លូវការចំពោះគាត់ មិនឲ្យធ្វើសេចក្តីថ្លែងការណ៍ណាមួយផ្សេងទៀតដែលមានលក្ខណៈស្រដៀងគ្នានេះ"[4]។

២- កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១២, ក្រុមមេធាវីការពារក្តីបានដាក់ "សេចក្តីបន្ថែម"មួយពីលើសំណើរបស់ខ្លួន ("សេចក្តីស្នើសុំបន្ថែម")[5]។ សំណើបន្ថែមនេះស្វែងរកសុំលើកឡើងបន្ថែមថាសេចក្តីថ្លែងការណ៍របស់លោក ហោ ណាំហុង បានជ្រៀតជ្រែកជាបន្ថែមទៀត នៅក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការដោយសារការគំរាមកំហែង ការបំភិតបំភ័យ ឬម្យ៉ាងទៀតដោយការ ជ្រៀតជ្រែកចំពោះសាក្សី ភី ភួន ដែលបានផ្តល់សក្ខីកម្មជាសាក្សីជូនអង្គជំនុំជម្រះសាលាដំបូងនៅមុនកាលបរិច្ឆេទនៃការធ្វើសេចក្តីថ្លែងការណ៍របស់ ហោ ណាំហុង ដែលត្រូវបានចោទប្រកាន់[6] ក្រុមមេធាវីការពារក្តីបានលើកឡើងថាសេចក្តីថ្លែងការណ៍នេះបានគាបសង្កត់លើ ភី ភួន ដើម្បីឲ្យ បដិសេធចោលនូវ ផ្នែកខ្លះនៃសក្ខីកម្មសាក្សីរបស់ខ្លួន[7] និងបានស្នើសុំផ្តល់ក្នុងនាមជាសំណងជួសជុល បន្ថែមមួយថា សុំឲ្យ

[1] **E219** សំណើអនុលោមតាមវិធាន៣៥ សុំឲ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងនឹងរដ្ឋមន្ត្រីការបរទេស ហោ ណាំហុង, ១៣ សីហា ២០១២ ("សំណើ")។ សំណើនេះបានជូនដំណឹងនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១២។

[2] **E219** សំណើ, កំណត់សម្គាល់*ខាងដើម* លេខ១ ត្រង់កថាខណ្ឌទី២៣(ខ)។ វិធាន៣៥(២)(ក) នៃវិធានផ្ទៃក្នុង អនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងចាត់ការលើឧទាហរណ៍ជាក់លាក់នៃការជ្រៀតជ្រែកជាបន្ទាន់។

[3] **E219** សំណើ, កំណត់សម្គាល់*ខាងដើម* លេខ១ ត្រង់កថាខណ្ឌទី១។

[4] **E219** សំណើ, កំណត់សម្គាល់*ខាងដើម* លេខ១ ត្រង់កថាខណ្ឌទី២៣(គ)។

[5] ឯកសារលេខ E219/1 សំណើសុំបន្ថែមពីលើសំណើសុំឲ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងនឹងលោករដ្ឋមន្ត្រីការបរទេស ហោ ណាំហុង អនុលោមតាមវិធាន៣៥នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី២៤ សីហា ២០១២។ ដែលបានជូនដំណឹងកាលពីថ្ងៃទី២៤ សីហា ២០១២។

[6] ឯកសារលេខ E219/1 សំណើសុំបន្ថែម, កំណត់សម្គាល់លេខ៥ *ខាងដើម* ត្រង់កថាខណ្ឌទី៤។

[7] ឯកសារលេខ E219/1 សំណើសុំបន្ថែម, កំណត់សម្គាល់លេខ៥ *ខាងដើម* ត្រង់កថាខណ្ឌទី៤,៥។

អង្គជំនុំជម្រះសាលាដំបូង "ដឹកនាំកិច្ចស៊ើបសួរបន្ថែមទៀតដើម្បីបញ្ជាក់ពីការពិតថា តើមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ដំណើរការនីតិវិធី ក្នុងការស៊ើបសួរប្រឆាំងនឹង ហោ ណាំហុង" អនុលោមតាមវិធាន៣៥.២.(ខ) នៃវិធានផ្ទៃក្នុងដែរ ឬទេ[8]។

៣- នៅក្នុងចម្លើយតបនេះ សហព្រះរាជអាជ្ញាជំទាស់នឹងសំណើរបស់មេធាវីការពារក្តី និងសេចក្តីបន្ថែម។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា មេធាវីការពារក្តីខកខានក្នុងការបង្ហាញភ័ស្តុតាងចំពោះការទាមទាររបស់ខ្លួន អំពីការជ្រៀតជ្រែងក្នុងកិច្ចការរដ្ឋបាលតុលាការតាមវិធាន៣៥ នៃវិធានផ្ទៃក្នុង ("វិធាន")។

## II. សំណើគួរត្រូវបានបដិសេធ

៤- វិធាន៣៥ ពាក់ព័ន្ធតែអំពើណាដែលមានតម្លៃស្មើនឹងការជ្រៀតជ្រែកក្នុង "កិច្ចការរដ្ឋបាលរបស់តុលាការ"។ គោលបំណងនៃវិធាននេះគឺ "ដើម្បីធានាថា ការអនុវត្តនូវយុត្តាធិការរបស់តុលាការ ពុំត្រូវបានរារាំង ហើយថាមុខងារជាមូលដ្ឋានរបស់តុលាការត្រូវបានការពារ"[9]។ នៅចុងបញ្ចប់នៃចំណុចនេះ គឺនៅលើ"ការអនុវត្ត*ដោយសុភវិនិច្ឆ័យ* ចំពោះវិធាននេះ នៅពេលដែល សចស ឬអង្គជំនុំជម្រះពិចារណាអំពីសកម្មភាពទាំងឡាយដែលបានប្រព្រឹត្តឡើងដោយបុគ្គលណាម្នាក់ ដែលគំរាមកំហែងដល់កិច្ចការរដ្ឋបាលរបស់តុលាការ" ដើម្បីការពារដំណើរការប្រកបដោយសុចរិតភាព[10]។ វិធាននេះមិនមែនជាយន្តការធ្វើឱ្យច្របូកច្របល់ដល់ពេលវេលា និងធនធានក្រខ្សត់របស់តុលាការនេះឡើយ។

៥- វិធាន៣៥(១)ចែងថាអង្គជំនុំជម្រះសាលាដំបូង "អាចដាក់ទណ្ឌកម្ម ឬបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ច នូវជនណាម្នាក់ដែលជ្រៀតជ្រែកដោយចេតនាពិតប្រាកដ ក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ" ឬញុះញង់ ឬប៉ុនប៉ងប្រព្រឹត្តអំពើដូច្នេះ[11]។ វិធាននេះផ្តល់បន្ថែមនូវបញ្ជីទម្រង់នៃការជ្រៀតជ្រែកដែលអាចនឹងកើតមាន[12]។ វិធាន៣៥(២) ចែងថា "នៅពេលដែលអង្គជំនុំជម្រះមានហេតុផល

---

[8] ឯកសារលេខ E219/1 សំណើសុំបន្ថែម, កំណត់សម្គាល់លេខ៥ *ខាងដើម* ត្រង់កថាខណ្ឌទី៧ (ដោយលុបចោលអត្ថបទដែលនៅក្នុងអព្ភន្តរសញ្ញា)។

[9] **E176/2** សេចក្តីសម្រេចលើសំណើសុំឱ្យចាត់ការជាបន្ទាន់តាមវិធាន៣៥ នៃវិធានផ្ទៃក្នុង, ១១ ឧសភា ២០១២, កថាខណ្ឌទី២១។

[10] **D314/2/7** សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ កសចស លើសំណើសុំឱ្យកោះហៅសាក្សី, ៨ មិថុនា ២០១០, កថាខណ្ឌទី៣៨ (សង្កត់ន័យត្រង់អក្សរទ្រេត)។

[11] វិធាន៣៥(១) & ៣៥(១)(ឆ)។

[12] វិធាន៣៥(១)(ក-ច)។

ជឿថា បុគ្គលណាម្នាក់អាចបានប្រព្រឹត្តអំពើណាមួយ ដូចមានចែងក្នុង[វិធាន៣៥(១)ខាងលើ] អង្គជំនុំជម្រះ អាច៖

ក- ចាត់ការជាមួយបញ្ហានេះជាបន្ទាន់

ខ- ដឹកនាំការស៊ើបសួរបន្ថែម ដើម្បីឲ្យដឹងប្រាកដថា តើមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ចាត់ការតាមនីតិវិធី ឬ

គ- បញ្ជូនបញ្ហានេះទៅឲ្យអាជ្ញាធរមានសមត្ថកិច្ច របស់ព្រះរាជអាជ្ញានៃព្រះរាជាណាចក្រកម្ពុជា ឬអង្គការសហប្រជាជាតិ”។

៦- ការវិភាគដែលពាក់ព័ន្ធ “មានជាប់ទាក់ទងទៅនឹងការវាយតម្លៃអំពីវត្តមាននៃ... អំពើ ឬការខកខានណាមួយដែលអាចឲ្យគេបកស្រាយបានថា ជាការគំរាមកំហែង ការបំភិតបំភ័យ ការបង្ករបួសស្នាម ការសូកប៉ាន់ ឬការជ្រៀតជ្រែក”[13] ទៅលើសាក្សីណាម្នាក់ ឬបុគ្គល ឬក្រុមពាក់ព័ន្ធដទៃផ្សេងទៀត។ គោលបំណងនៃការហាមឃាត់ចំពោះអំពើណាមួយ ដែលមានទំនោរធ្វើឲ្យខូចដល់ផលប្រយោជន៍នៃកិច្ចការរដ្ឋបាលរបស់តុលាការ គឺដើម្បីធានាថា ការអនុវត្តនូវយុត្តាធិការរបស់តុលាការពុំត្រូវបានរារាំង ហើយថាមុខងារតុលាការជាមូលដ្ឋានត្រូវបានការពារ។ ការណ៍នេះតម្រូវច្បាស់ណាស់ថា តួអង្គពីខាងក្រៅត្រូវបានរារាំងមិនឲ្យមានឥទ្ធិពលទៅលើចៅក្រមរបស់តុលាការ [សាក្សី ឬក្រុមពាក់ព័ន្ធដទៃទៀត] ឬពីការធ្វើសកម្មភាពបែបណាមួយដែលអាចឲ្យគេមើលឃើញថា ជាការប៉ុនប៉ងធ្វើដូច្នេះមែន”[14]។ វាមិនសំខាន់ទេថាតើសាក្សី [ឬក្រុមពាក់ព័ន្ធដទៃទៀត] ពិតជាទទួលអារម្មណ៍ថា ត្រូវបានគេគំរាមកំហែង ឬបំភិតបំភ័យ ធ្វើឲ្យរាងចាល ឬទទួលរងឥទ្ធិពលនោះ”[15]។

៧- ដើម្បីរារាំងការរំលោភបំពានទៅលើវិធាន៣៥ ដើម្បីផ្តោតការយកចិត្តទុកដាក់លើបញ្ហាទាំងឡាយដែលស្ថិតក្នុងគោលដៅរបស់ខ្លួន និងដើម្បីការពារមូលដ្ឋានសមហេតុផលនៃការបញ្ចេញមតិដោយសេរី

---

[13] **D314/2/7** សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ កសចស លើសំណើសុំឲ្យកោះហៅសាក្សី, ៨ មិថុនា ២០១០, កថាខណ្ឌទី៣៨។

[14] **E176/2** សេចក្តីសម្រេចលើសំណើសុំឲ្យមានចំណាត់ការជាបន្ទាន់, ១១ ឧសភា ២០១២, កថាខណ្ឌទី២១ (លប់ចោលត្រង់សេចក្តីយោងខាងក្នុង)។

[15] **D314/2/7** សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ កសចស លើសំណើសុំឲ្យកោះហៅសាក្សី, ៨ មិថុនា ២០១០, កថាខណ្ឌទី៤០ ដោយដកស្រង់រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Haraqija និង Morina,* សំណុំរឿងលេខ IT-04-84-R77.4, សាលក្រមអំពីការប្រមាថ, តុលាការ ICTY, ១៧ ធ្នូ ២០០៨, កថាខណ្ឌទី១៨-២០។

វិធាន៣៥ដាក់លក្ខខណ្ឌភ័ស្តុតាងថាភាគីដែលស្នើសុំ ត្រូវបំពេញឲ្យបាន ដើម្បីឲ្យមានឧបាស្រ័យតាមបទប្បញ្ញត្តិនៃវិធាន៣៥ ដំណើរការទៅបាន៖

> *យោងតាមវិធាន៣៥(២) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះដែលបានទទួលការចោទប្រកាន់នៃការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាល អាចធ្វើចំណាត់ការត្រឹមតែក្រោមវិធាននេះប៉ុណ្ណោះ បើសិនជាខ្លួនមានហេតុផលនាំឲ្យជឿបានថា បុគ្គលនោះអាចបានជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ...។ នេះជាលក្ខខណ្ឌកម្រិតអប្បបរមាសម្រាប់ការស៊ើបសួរ ដែលធ្វើឲ្យមានប្រតិកម្មឡើង តាមរយៈ "ហេតុផលនាំឲ្យជឿបាន"ថា ទង្វើដែលមានសក្តានុពលដល់ការគំរាមកំហែងចំពោះកិច្ចការរដ្ឋបាលរបស់តុលាការអាចនឹងកើតមានឡើង។ វាគ្រាន់តែផ្តល់ឲ្យមានការស្រាវជ្រាវបន្ថែមប៉ុណ្ណោះ ហើយមិនចាំបាច់តម្រូវឲ្យអង្គជំនុំជម្រះចូលរួមពាក់ព័ន្ធក្នុងការពិនិត្យល្អិតល្អន់លើអង្គសេចក្តីនៃការចោទប្រកាន់ ឬការសង្ស័យអំពីការជ្រៀតជ្រែក ឬវាយតម្លៃអំពីបញ្ហានៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គលឡើយ។ លក្ខខណ្ឌកម្រិតនេះនឹងត្រូវបានបំពេញ ដរាបណាមូលដ្ឋានជាក់ស្តែងសម្រាប់ការចោទប្រកាន់ មានហេតុផលនាំឲ្យអង្គជំនុំជម្រះជឿបានថា ការចោទប្រកាន់នោះមិនមែនគ្រាន់ជាការស្មានៗទេ។ បើសិនជាមានហេតុផលឲ្យជឿថា មានបុគ្គលណាម្នាក់អាចបានជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការនោះ អង្គជំនុំជម្រះ..អាច ប៉ុន្តែមិនចាំបាច់ត្រូវតែធ្វើនោះទេ ធ្វើចំណាត់ការមួយ ឬច្រើន ដូចមានចែងក្នុងវិធាន៣៥(២) ដែលវិធាននេះរួមបញ្ចូលការធ្វើចំណាត់ការចំពោះបញ្ហាជាបន្ទាន់[16]។*

អង្គជំនុំជម្រះតុលាការកំពូលក៏បានបញ្ជាក់ផងដែរថា សូម្បីតែមានសំណើមួយដែលមានសំអាងហេតុតាមអ្វីដែលមានចែងក្នុងវិធាន៣៥ក៏ដោយ ក៏ចំណាត់ការត្រូវស្ថិតក្នុងឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង[17]។ មានសេចក្តីបន្ថែមយ៉ាងដូច្នេះថា៖

---

[16] **E176/2** សេចក្តីសម្រេចលើសំណើសុំឲ្យមានចំណាត់ការជាបន្ទាន់, ១១ ឧសភា ២០១២, កថាខណ្ឌទី២០ (លុបចោលត្រង់សេចក្តីយោងខាងក្នុង)។

[17] **E116/1/7** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, ២៧ មេសា ២០១២, កថាខណ្ឌទី៣៨ និងកំណត់សម្គាល់ជើងទំព័រ៨៧ ("វិធាន៣៥ ផ្តល់អំណាចខាងឆន្ទានុសិទ្ធិឲ្យចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះ ចាត់ការលើបញ្ហានៃការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការ ដូចបានគូសបញ្ជាក់ក្នុងកថាខណ្ឌទី១ និងទី២ របស់ខ្លួនដែលប្រើពាក្យថា "អាច")។

*ការរកឃើញថា មានហេតុផលឲ្យជឿបាន មិនតម្រូវ ឬមិនពាក់ព័ន្ធទៅនឹងការកំណត់សម្រេចលើអង្គសេចក្តីនៃការចោទប្រកាន់ ឬការសង្ស័យអំពីការជ្រៀតជ្រែកឡើយ។ ប៉ុន្តែការរកឃើញថាមានហេតុផលឲ្យជឿបានថា បទដ្ឋានត្រូវបានបំពេញ តម្រូវឲ្យ...អង្គជំនុំជម្រះធ្វើការសន្និដ្ឋានថា មានមូលដ្ឋាន ឬហេតុផលជាក់ស្តែង ដែលនេះជាមូលដ្ឋានគ្រឹះនៃ* ជំនឿ*របស់ខ្លួន។ មូលដ្ឋាន ឬហេតុផលជាក់ស្តែងនេះ ត្រូវតែបង្កើតឲ្យបាន ដោយឈរលើមូលដ្ឋាននៃការពិនិត្យទៅលើការចោទប្រកាន់ ឬការសង្ស័យ ដែលការពិនិត្យនេះអាចជាកត្តាអត្តនោម័ត*[18] ។

៨- តាមការយល់ឃើញរបស់សហព្រះរាជអាជ្ញា សេចក្តីណែនាំបន្ថែមរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងការប្រព្រឹត្តិទៅនៃវិធាន៣៥ នឹងនាំមកនូវភាពច្បាស់លាស់មួយដែលមានប្រយោជន៍ដល់ ការបកស្រាយ ប៉ុន្តែមិនចាំបាច់ជាក់លាក់នោះទេ ចំពោះដំណោះស្រាយលើសំណើមួយនេះ។ ពាក់ព័ន្ធនឹងលក្ខខណ្ឌនៃការបង្ហាញភ័ស្តុតាងដែលត្រូវឆ្លើយតប ដើម្បីចាត់ការជាបន្ទាន់ តាមវិធាន៣៥.២ នោះអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ដូចបានថ្លែងនៅខាងលើស្រាប់ គេអាចប្រើចំណាត់ការជាបន្ទាន់សម្រាប់ការស្វែងរកនូវជំនឿសមហេតុផលណាមួយ[19]។ យ៉ាងដូច្នេះក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានថ្លែងផងដែរថា ការរកឃើញជំនឿសមហេតុផលណាមួយ គឺជា "លក្ខខណ្ឌបទដ្ឋានអប្បបរមា សម្រាប់បើកការស៊ើបអង្កេត" ដែល "នាំឲ្យមានត្រឹមតែការស៊ើបអង្កេតបន្ថែម" និងមិនមានជាប់ទាក់ទងទៅនឹង "ការពិនិត្យជាលម្អិតទៅលើខ្លឹមសារនៃការចោទប្រកាន់ណាមួយ" ឡើយ[20]។ អង្គបុរេជំនុំជម្រះធ្លាប់បានឯកភាពថា "បទដ្ឋានដែលតម្រូវឲ្យមាន*មូលហេតុអាចឲ្យជឿបាន* គឺជាបទដ្ឋានដែលមានលក្ខណៈស្រាលបំផុត និងអាចឲ្យមានការស៊ើបសួរពី... អង្គជំនុំជម្រះណាមួយ"[21]។ សហព្រះរាជអាជ្ញាបានទទួលស្គាល់ថា អនុប្រយោគនៅក្នុងវិធាន៣៥.២.ក បានអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូង "ចាត់ការជាមួយបញ្ហានេះជាបន្ទាន់" ដែលក្តោបទៅលើចំណាត់ការសក្តានុពលជា

---

[18] **D314/1/12** សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ កសចស លើសំណើសុំឲ្យកោះហៅសាក្សី, ៨ មិថុនា ២០១០, កថាខណ្ឌទី៣៧ (សង្កត់ន័យត្រង់ឃ្លាដើម)។

[19] **E176/2** សេចក្តីសម្រេចលើសំណើសុំឲ្យចាត់ការជាបន្ទាន់ តាមវិធាន៣៥ នៃវិធានផ្ទៃក្នុង, ថ្ងៃទី១១ ឧសភា ២០១២, កថាខណ្ឌទី២០ (សេចក្តីយោងផ្ទៃក្នុងត្រូវបានលុបចោល)។

[20] **E176/2** សេចក្តីសម្រេចលើសំណើសុំឲ្យចាត់ការជាបន្ទាន់ តាមវិធាន៣៥ នៃវិធានផ្ទៃក្នុង, ថ្ងៃទី១១ ឧសភា ២០១២, កថាខណ្ឌទី២០ (សេចក្តីយោងផ្ទៃក្នុងត្រូវបានលុបចោល)។

[21] **D314/1/12** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា និងលោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់ កសចស លើសំណើសុំឲ្យកោះហៅសាក្សី, ថ្ងៃទី៨ មិថុនា ២០១០, កថាខណ្ឌទី៣៧ (សង្កត់ន័យបន្ថែមដើមដោយ*អក្សរទ្រេត*)។

ច្រើន ដែលមានចំណាត់ការខ្លះដូចជា ការបដិសេធសំណើណាមួយ អាចមិនចាំបាច់ធ្វើការស្វែងរកភ័ស្តុតាងបន្ថែមទៀត ឲ្យហួសពី "មូលហេតុដែលអាចឲ្យជឿបាន" នោះឡើយ។ យ៉ាងដូច្នេះក៏ដោយក៏វាមុខជានឹងមានភាពលើសលប់ជាមិនខាន បើសិនជាលក្ខខណ្ឌបទដ្ឋានអប្បបរមាដែលនាំឲ្យមានត្រឹមតែ*ការស៊ើបអង្កេត* មានដូចគ្នានឹងបទដ្ឋាននៃភ័ស្តុតាង សម្រាប់សម្រេចឲ្យមានចំណាត់ការបន្ទាន់ដែលបានរិះគន់នោះ[22]។ អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា កាលណាចំណាត់ការបន្ទាន់នោះមានជាប់ទាក់ទងនឹងការកំណត់ពិរុទ្ធភាព ដូចដែលដំណោះស្រាយរបស់មេធាវីការពារក្តីបានស្នើសុំនៅទីនេះ នោះបទដ្ឋានភ័ស្តុតាងគឺចាំបាច់ត្រូវតែមានលក្ខណៈខ្ពស់ជាង។ ការណ៍នេះ ត្រូវបានអះអាងបញ្ជាក់ដោយយុត្តិសាស្ត្រនៃតុលាការ ICTY ដែលពាក់ព័ន្ធនឹងចំណាត់ការតាមវិធាន៧៧ ដែលថាអង្គជំនុំជម្រះសាលាដំបូងនេះធ្លាប់បានធ្វើការយោងពីមុនមក ដែលតម្រូវឲ្យមានភ័ស្តុតាង "ហួសពីវិមតិសង្ស័យ" ដើម្បីស្វែងរកពិរុទ្ធភាព[23]។ អង្គជំនុំជម្រះសាលាដំបូងខ្លួនឯងធ្លាប់បានធ្វើការអះអាងថា "ជាមួយវិធាន ៧៧ នៃតុលាការ ICTY កិច្ចដំណើរការនីតិវិធីអនុលោមតាមវិធាន៣៥ នៃវិធានផ្ទៃក្នុង គឺជាកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ទើបចំណុះឲ្យគោលការណ៍ធម្មតានៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ"[24]។ អង្គជំនុំជម្រះតុលាការកំពូលក៏ធ្លាប់បានបញ្ជាក់ដូចគ្នានេះដែរ

---

[22] អង្គបុរេជំនុំជម្រះធ្លាប់បានថ្លែងថា ចំណុចចាប់ផ្តើមនៃ "មូលដ្ឋានគ្រប់គ្រាន់" គឺមានលក្ខណៈចាំបាច់ក្នុងការប្រើប្រាស់នូវវិធានការណាមួយក៏ដោយ ដែលមាននៅក្នុងវិធាន៣៥.២ ទោះបីជាគេបានលើកឡើងពី "មូលដ្ឋានគ្រប់គ្រាន់" នោះនៅក្នុងវិធាន៣៥.២.ខ តែប៉ុណ្ណោះក៏ដោយ។ **D314/1/12** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា និងលោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់ កសចស លើសំណើសុំឲ្យកោះហៅសាក្សី, ថ្ងៃទី៨ មិថុនា ២០១០, កថាខណ្ឌទី៣៦ ("បទដ្ឋានដែលតម្រូវឲ្យមាន *មូលដ្ឋានគ្រប់គ្រាន់* ត្រូវតែបំពេញ ដើម្បីឲ្យមានការបើកកិច្ចដំណើរការនីតិវិធី ចាត់ការបញ្ហានោះភ្លាមៗ ឬបញ្ជូនបញ្ហានោះទៅស្ថាប័នមានសមត្ថកិច្ចរបស់ប្រទេសកម្ពុជា ឬរបស់អង្គការសហប្រជាជាតិ")។ បន្ថែមលើនេះ តាមនិយមន័យរបស់អង្គបុរេជំនុំជម្រះផ្ទាល់នោះគឺថា និយមន័យរបស់អង្គបុរេជំនុំជម្រះស្តីពី "មូលដ្ឋានគ្រប់គ្រាន់" នោះក៏ពុំមែនជាបទដ្ឋានមួយដ៏ខ្ពស់គ្រប់គ្រាន់ល្មមក្នុងការកំណត់ពីការប្រព្រឹត្តខុសនោះដែរ៖ "បទដ្ឋានដែលទាមទារឲ្យមាន*មូលដ្ឋានគ្រប់គ្រាន់* តម្រូវឲ្យអង្គជំនុំជម្រះសាលាដំបូង គ្រាន់តែបង្ហាញថាតើភ័ស្តុតាងមាននៅចំពោះមុខខ្លួន បង្ហាញជា*បឋម* ថាមានករណីប្រមាថតុលាការ ដែរឬទេ ហើយមិនតម្រូវឲ្យធ្វើការសម្រេចចុងក្រោយថា តើមានការប្រមាថដែរ ឬទេ នោះឡើយ" *ដដែលដូចមុន* កថាខណ្ឌទី៣៨។

[23] *នៅក្នុងករណី Matter of Vojislav Šešelj,* សំណុំរឿងលេខ IT-03-67-R77.4, សំណៅកោសលុបចេញខ្លះសម្រាប់សាធារណជនស្តីពីសេចក្តីសម្រេចចេញនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១២, តុលាការ ICTY, ថ្ងៃទី២៨ មិថុនា ២០១២, កថាខណ្ឌទី៤២។ *សូមមើលផងដែរ រដ្ឋអាជ្ញា ទល់នឹង Vojislav Šešelj,* សំណុំរឿងលេខ IT-03-67-AR77.2, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អយ្យការប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៨, ថ្ងៃទី២៥ កក្កដា ២០០៨, តុលាការ ICTY, កថាខណ្ឌទី១៦ ("អង្គជំនុំជម្រះសាលាឧទ្ធរណ៍រំឮកថា...បទដ្ឋាន"មូលដ្ឋានគ្រប់គ្រាន់" តាមវិធាន៧៧.ឃ នៃវិធានផ្ទៃក្នុង តម្រូវឲ្យអង្គជំនុំជម្រះសាលាដំបូងគ្រាន់តែឲ្យបង្ហាញ ថាតើភ័ស្តុតាងនៅចំពោះមុខខ្លួនបានលើកឡើងពីករណីស្តីពី*ការឃើញមួយក្រឡេកភ្នែក (prima facie)* នៃការប្រមាថលើអង្គជំនុំជម្រះដែរ ឬមួយយ៉ាងណា ហើយពុំមែនឲ្យធ្វើការស្រាវជ្រាវរកមើលថាតើគេបានប្រព្រឹត្តការប្រមាថនោះហើយ ឬនៅនោះ ទេ")។

[24] **E176/2** សេចក្តីសម្រេចលើសំណើសុំឲ្យចាត់ការជាបន្ទាន់ តាមវិធាន៣៥ នៃវិធានផ្ទៃក្នុង, ថ្ងៃទី១១ ឧសភា ២០១២, កំណត់សម្គាល់ជើងទំព័រលេខ២៨។

ថា ការរកឃើញការប្រព្រឹត្តអាក្រក់ តាមវិធាន៣៥.១ ត្រូវតែត្រូវទៅតាមបទដ្ឋានមួយ ដែល "ហួសពីវិមតិសង្ស័យ"[25]។

៩- លើសពីនេះទៀត សហព្រះរាជអាជ្ញាជូនសេចក្ដីសន្និដ្ឋានថា ភាគីដែលស្នើសុំ មិនត្រឹមតែត្រូវបង្ហាញថា អំពើ ឬការខកខានដែលបង្កើតបានជាការជ្រៀតជ្រែកនោះ ត្រូវធ្វើទៅតាមបទដ្ឋានពាក់ព័ន្ធប៉ុណ្ណោះ ត្រូវបង្ហាញថាត្រូវបានគេប្រព្រឹត្តឡើងដោយមាន *បំណងឧក្រិដ្ឋ*មួយ "ដោយចេតនាពិតប្រាកដ" ថែមទៀតផង។ មានភាពតានតឹងមួយចំនួននៅក្នុងសេចក្ដីសម្រេចនានាពីមុនរបស់អង្គជំនុំជម្រះសាលាដំបូងលើបញ្ហានេះ។ នៅក្នុងសេចក្ដីសម្រេចមួយ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា កាលណាមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដែលត្រូវចោទប្រកាន់ដែលភាគីស្នើសុំ ត្រូវតែធ្វើការបង្ហាញថា អំពើដែលបានចោទប្រកាន់នោះ ត្រូវបានគេប្រព្រឹត្តឡើង "ដោយចេតនាពិតប្រាកដ" ក្នុងការប៉ុនប៉ងមួយ ដើម្បីជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ[26]។ យ៉ាងដូច្នេះក៏ដោយ ក៏នៅក្នុងសេចក្ដីសម្រេចមួយផ្សេងទៀត អង្គជំនុំជម្រះសាលាដំបូងបានធ្វើការសម្រេចយ៉ាងច្បាស់លាស់ថា "ការធ្វើអន្តរាគមន៍ ដោយអនុលោមតាមវិធាននេះ អាចធ្វើទៅបាន លុះត្រាតែមានការជឿជាក់ដោយមានហេតុផលសមស្របថា បុគ្គលម្នាក់នោះបានជ្រៀតជ្រែកកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ "ដោយចេតនាពិតប្រាកដ"[27]។

១០- នៅក្នុងសំណើបន្ទាន់មួយនេះ មេធាវីការពារក្ដីមិនបានលើកឡើងពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌមកចោទប្រកាន់ទេ។ ប៉ុន្តែគេបានស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការដោះស្រាយលើបញ្ហានេះ ដោយ

[25] **E116/1/7** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, ថ្ងៃទី២៧ មេសា ២០១២, កថាខណ្ឌទី៣៦ ("ប្រសិនបើត្រូវបានបង្ហាញឲ្យឃើញហួសពីវិមតិសង្ស័យរួចហើយនោះ ការលាតត្រដាងឯកសារដែលត្រូវបានធ្វើចំណាត់ថ្នាក់រួចហើយ គឺជាបទល្មើសមួយប្រភេទ អនុលោមវិធាន៣៥.១.ក នៃវិធានផ្ទៃក្នុង ដែលអាចបណ្ដាលឲ្យមានការដាក់ទណ្ឌកម្មស្របតាមច្បាប់កម្ពុជា ៧៩ និង/ឬ ក៏ជាកំហុសវិជ្ជាជីវៈរបស់មេធាវី")។

[26] **E176/2** សេចក្ដីសម្រេចលើសំណើសុំឲ្យចាត់ការជាបន្ទាន់ តាមវិធាន៣៥ នៃវិធានផ្ទៃក្នុង, ថ្ងៃទី១១ ឧសភា ២០១២, កថាខណ្ឌទី២២។

[27] **E142/3** សេចក្ដីសម្រេចលើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន៣៥ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងនៃការស្ដាប់ចម្លើយសាក្សីរបស់ កសចស, ថ្ងៃទី១៣ មីនា ២០១២, កថាខណ្ឌទី៩។ *សូមមើលផងដែរ ដដែលដូចខាងលើ* ត្រង់កថាខណ្ឌទី១៣ (ដោយបានបញ្ជាក់អះអាងឡើងវិញថា បំណងឧក្រិដ្ឋ (*mens rea*) ដោយមានចេតនាពិតប្រាកដ ត្រូវតែបានបង្ហាញនៅក្នុងដំណាក់កាលដាក់សំណើ៖ "នៅក្នុងការចោទប្រកាន់អំពីចំណុចខ្វះចន្លោះរវាងកំណត់ហេតុជាខ្សែអាត់សម្លេង និងចម្លើយជាលាយលក្ខណ៍អក្សរ មេធាវីពុំបានបង្ហាញ ឬពុំបានព្យាយាមចង្អុលបង្ហាញថាបុគ្គលិក កសចស ពិតជាបានបំប្លែងកំណត់ហេតុនៃកិច្ចស៊ើបសួរដោយចេតនាពិតប្រាកដឡើយ...")។

“ចាត់ចំណាត់ការជាបន្ទាន់”[28]។ វិធាន៣៥.១ អនុវត្តបទដ្ឋាន “ដោយចេតនាពិតប្រាកដ” ចំពោះ “ទណ្ឌកម្ម” ណាមួយក៏ដោយដែលបានដាក់ដោយអង្គជំនុំជម្រះសាលាដំបូង ដូចដែលត្រូវបានពណ៌នាក្រោយមកទៀតនៅក្នុងវិធាន៣៥.២។ “ទណ្ឌកម្ម”ជាសក្ខានុពលមួយក្នុងចំណោមនោះ គឺអង្គជំនុំជម្រះសាលាដំបូងអាច“ចាត់ការជាមួយបញ្ហានេះជាបន្ទាន់[29]។ អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញាស្នើដោយគោរពថា ការចោទប្រកាន់ពីការជ្រៀតជ្រែកណាមួយក៏ដោយ តាមវិធាន៣៥ ត្រូវតែមាន *បំណងឧក្រិដ្ឋ* មួយ “ដោយចេតនាពិតប្រាកដ” ដោយមិនគិតពី ថាតើការទទួលខុសត្រូវ *ផ្នែកព្រហ្មទណ្ឌ* ត្រូវបានចោទប្រកាន់ដែរ ឬមួយយ៉ាងណានោះឡើយ[30]។ ដូចដែលតុលាការ ICTY ធ្លាប់បានថ្លែងពាក់ព័ន្ធទៅនឹងវិធាន៧៧ ថា “ចំពោះ*អំពើពិរុទ្ធ*នីមួយៗដែលក្តោបដោយវិធាន៧៧.ក ភាគីដែលបានលើកសំណើត្រូវតែបង្ហាញថា ជនជាប់ចោទបានប្រព្រឹត្តដោយមានចេតនាពិតប្រាកដ គឺថាដោយមានចេតនាជាក់លាក់នេះ អំពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ។ ចេតនាបែបដូច្នេះអាចនឹងត្រូវបានបង្ហាញដោយឡែក ឬទាញសេចក្តីសន្និដ្ឋានចេញពីអង្គហេតុនានា ទៅតាមករណីនីមួយៗ”[31]។ មេធាវីការពារក្តីទំនងជាឯកភាពថា គាត់ត្រូវតែបង្ហាញពីបទដ្ឋានដែលមានចេតនាពិតប្រាកដ និងការដឹងឮ[32]។

១១- ដោយមិនគិតពី សូម្បីតែចំណាត់ការជាបន្ទាន់អាចត្រូវបានធ្វើឡើង ទៅតាមបទដ្ឋាន “មូលហេតុអាចឲ្យជឿបាន” និងដោយពុំមានបង្ហាញពី *បំណងឧក្រិដ្ឋ* ក៏ដោយ ក៏ភាគីដែលដាក់សំណើត្រូវតែបង្ហាញពី “មូលដ្ឋានជាក់លាក់ ឬ *មូលហេតុ* ដែលជាមូលដ្ឋាននៃ *ជំនឿ* របស់ខ្លួន... ដោយផ្អែកលើការពិនិត្យ លើ

[28] **E219** សំណើ, កំណត់សម្គាល់*ខាងលើ* លេខ១ ត្រង់កថាខណ្ឌទី២៣.គ។

[29] វិធាន ៣៥.២.ក

[30] គោលជំហរនេះទំនងជាត្រូវបានគាំទ្រដោយអង្គជំនុំជម្រះតុលាការកំពូល។ *សូមមើល* **E130/4/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យជនជាប់ចោទមានវត្តមានក្នុងសាលសវនាការ, ថ្ងៃទី១៣ មករា ២០១២, ទំព័រទី២ (ដោយបានកត់សម្គាល់ថា ទណ្ឌកម្មពុំមែនជាផ្នែកព្រហ្មទណ្ឌដែលបានដាក់ដោយអង្គជំនុំជម្រះសាលាដំបូង មិនអាចបង្កើតបានជា “ការជ្រៀតជ្រែកដោយដឹង និងមានចេតនា ទៅលើកិច្ចការរដ្ឋបាលតុលាការ ដោយយោងទៅតាមអត្ថន័យនៃវិធាន៣៥ នៃវិធានផ្ទៃក្នុងឡើយ ”) ។

[31] *រដ្ឋអាជ្ញា ទល់នឹង Beqa Beqa*, សំណុំរឿងលេខ IT-03-66-T-R77, សេចក្តីសម្រេចលើការប្រមាថចោទប្រកាន់, តុលាការ ICTY, ថ្ងៃទី២៧ ឧសភា ២០០៥, កថាខណ្ឌទី២២។

[32] **E219** សំណើ, កំណត់សម្គាល់*ខាងលើ* លេខ១ ត្រង់កថាខណ្ឌទី១០ (“ដោយពិចារណាលើធាតុផ្សំសត្យានុម័តដែលមានចែងនៅវិធាន៧៧(ក)...”) និង កថាខណ្ឌទី១២ (“ក្នុងករណីនេះ វាឆ្លុះបញ្ចាំងយ៉ាងច្បាស់ថា ហោ ណាំហុង ប្រព្រឹត្តដោយចេតនា និងដោយដឹងជាមុនថាអំពើរបស់គាត់ គឺរំខាន ឬ ជះឥទ្ធិពលមកលើសាក្សី ឬសាក្សីសក្តានុពល”)។

ការចោទប្រកាន់” ដែរ[33]។ ការពិនិត្យមួយទៅលើចម្លើយដែលភ្ជាប់ទៅនឹង ហោ ណាំហុង និងអំណះអំណាងនានារបស់មេធាវីការពារក្តីនៅក្នុងការគាំទ្រដល់សំណើរបស់ពួកគេ មិនបានបង្ហាញពីមូលដ្ឋានតាមផ្លូវច្បាប់មួយទេ។ ដូចដែលសហព្រះរាជអាជ្ញាបានលើកស្នើឡើងដូច្នោះដែរ សំណើរបស់មេធាវីការពារក្តី គឺស្ថិតនៅឆ្ងាយពីការអនុវត្តទៅតាមបទដ្ឋានខ្ពស់មួយនៃការបង្ហាញភស្តុតាង និងឆ្ងាយពី *បំណងឧក្រិដ្ឋ* មួយ “ដោយចេតនាពិតប្រាកដ និងដឹងឮ” ថែមទៀតផង។

១២-នៅក្នុងសេចក្តីថ្លែងការណ៍នោះទាំងមូលបានចោទប្រកាន់ថា បានជ្រៀតជ្រែកចូលនៅក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការ៖

> *វាជារឿងអកុសល ដែលអ្នកបន្តការពារកេរ្តិ៍ដំណែលរបស់ខ្មែរក្រហមខិតខំបង្វែរការយកចិត្តទុកដាក់ចេញពីកេរ្តិ៍មិតករបស់ខ្មែរក្រហម ក្នុងផលប្រយោជន៍នៃការការពាររបស់គេដែលបង្កហេតុឲ្យមានការយល់ច្រឡំមកលើឥស្សរជនសាធារណៈដូចជារូបខ្ញុំ។ ខ្ញុំចង់និយាយយ៉ាងខ្លីពីប្រវត្តិរបស់ខ្ញុំ ដើម្បីជម្រះឲ្យអស់នូវការខ្វែងគំនិតទាំងនេះ។ របបខ្មែរក្រហមគឺជារឿងសោកនាដកម្មមួយដែលនៅដក់ជាប់ នៅក្នុងអារម្មណ៍របស់ប្រជាជនកម្ពុជារហូតដល់សព្វថ្ងៃ។ ក្នុងនាមជាអ្នកទោសនៅក្នុងជំរុំបឹងត្របែកដែលនៅទីនោះខ្ញុំបានបាត់បង់ប្អូនស្រីពីរនាក់ ព្រមទាំងស្វាមី និងកូនរបស់គេ និងក្មួយស្រីម្នាក់ ក៏ដូចជាសហជីវិនជាច្រើន ខ្ញុំគ្មានអ្វីក្រៅពីការសោកស្តាយ និងការរំលែកទុក្ខលំបាករបស់ជនរងគ្រោះនិងក្រុមគ្រួសាររបស់គេ។ សូម្បីតែមកដល់សព្វថ្ងៃនេះក្តី ក៏ប្រជាជនកម្ពុជានៅតែបន្តរងទុក្ខដោយសារឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម។ ពួកខ្មែរក្រហមមិនគ្រាប់តែបានបំផ្លាញមនុស្សអស់មួយជំនាន់នោះទេ តែក៏បានបំផ្លាញស្ទើរតែទាំងអស់ផងដែរនូវអរិយធម៌ខ្មែរដែលមកទល់ពេលនេះយើងកំពុងតែបន្តស្តារឡើងវិញ។ អង្គជំនុំជម្រះវិសាមញ្ញ គឺជាតុលាការច្បាប់ មិនមែនជាវេទិកានយោបាយនោះទេ។ ហើយខ្ញុំជឿជាក់ថា ការប៉ុនប៉ងធ្វើនយោបាយភាវូបនិយកម្មតុលាការនេះ ឬការធ្វើឲ្យមានការខ្វែងគំនិតគ្នា គឺជាទង្វើមិនសមស្របទេ។*

[33] **D314/1/12** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា និងលោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់ កសចស លើសំណើសុំឲ្យកោះហៅសាក្សី, ថ្ងៃទី៨ មិថុនា ២០១០, កថាខណ្ឌទី៣៧ (សង្កត់ន័យបន្ថែមដើមដោយ*អក្សរទ្រេត*)។

> *ការសង្ឃឹមដ៏ធំធេងរបស់ខ្ញុំ គឺជាថ្ងៃយុត្តិធម៌មួយ នឹងរកឃើញនូវយុត្តិធម៌ និងកេរ្តិ៍ដំណែលរបស់ខ្មែរក្រហម ដែលនឹងត្រូវបោះចោល នៅក្នុងធុងសម្រាមប្រវត្តិសាស្ត្រ ដោយលែងមានអ្នកការពារ ឬការខ្វែងគំនិតគ្នាទៀត។*

១៣-អង្គជំនុំជម្រះសាលាដំបូងមិនចាំបាច់ពិនិត្យមើលអ្វី ក្រៅពីអត្ថបទដោយផ្ទាល់អំពីសេចក្តីថ្លែងការណ៍ដែលត្រូវបានចោទប្រកាន់នោះទេ ដើម្បីកំណត់ថាសេចក្តីថ្លែងការណ៍នោះមិនចោទជាការជ្រៀតជ្រែកចូលនៅក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការឡើយ។ នៅក្នុងសេចក្តីថ្លែងការណ៍នោះគ្មានការគំរាមកំហែង ឬការបំភិតបំភ័យ ហើយថែមទាំងបានបញ្ជាក់ម្តងហើយម្តងទៀតថា អវតក "ជាតុលាការច្បាប់ និងមិនមែនជាវេទិការនយោបាយនោះទេ"។

១៤- គឺវាមានប្រយោជន៍ណាស់ក្នុងការធ្វើឲ្យមានភាពខុសគ្នារវាងសេចក្តីថ្លែងការណ៍ដែលបានធ្វើឡើងដោយ ហោ ណាំហុង និងសេចក្តីថ្លែងដែលមេធាវីការពារក្តីលើកឡើងដែលថា សេចក្តីថ្លែងការណ៍របស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលជាកម្មវត្ថុនៃការសម្រេចពីលើកមុនដោយអង្គជំនុំជម្រះអនុលោមតាមវិធាន៣៥ នៃវិធានផ្ទៃក្នុង។ ដែលនៅទីនោះ មេធាវីការពារក្តីបានចោទប្រកាន់ថាសម្តេចនាយករដ្ឋមន្ត្រីបានថ្លែងថា "ឃាតករ និងជនដៃដល់នៃអំពើប្រល័យពូជសាសន៍ (ចារី) កំពុងតែការពារខ្លួន ដែលជាកិច្ចខំប្រឹងប្រែងមួយ ដើម្បីគេចពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានា។ គេគ្រប់គ្នាបានដឹងថា ប្រទេសរបស់យើងធ្លាប់មានរបបប្រល័យពូជសាសន៍ [ឥឡូវនេះ] យើង និងពិភពលោក បានកំពុងដំណើរការកាត់ទោសពួកគេ"[34]។ សេចក្តីថ្លែងការណ៍របស់សម្តេចនាយករដ្ឋមន្ត្រីដែលលើកឡើងសំដៅទៅលើជនជាប់ចោទម្នាក់ដោយចំឈ្មោះ (ក៏ដូចជាជនជាប់ចោទជាក្រុមដែរ) និងបានថ្លែងថា គាត់មានពិរុទ្ធ "ជាឃាតករ និងជាជនដៃដល់នៃអំពើប្រល័យពូជសាសន៍ (ចារី)"[35]។ អង្គជំនុំជម្រះបានរកឃើញថា ការចោទប្រកាន់អំពីការធ្វើសេចក្តីអត្ថាធិប្បាយរបស់លោក

---

[34] ឯកសារលេខ **E176/2** សេចក្តីសម្រេចលើលើសំណើសុំឲ្យចាត់វិធានការណ៍ជាបន្ទាន់តាមវិធាន៣៥នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១១ ឧសភា ២០១២, កខាខណ្ឌទី៨។

[35] ឯកសារលេខ **E176/2** សេចក្តីសម្រេចលើសំណើសុំឲ្យចាត់វិធានការណ៍ជាបន្ទាន់តាមវិធាន៣៥នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១១ ឧសភា ២០១២, កថាខណ្ឌទី៨-៩។ អង្គជំនុំជម្រះសាលាដំបូងបានបានបញ្ជាក់ម្តងហើយម្តងទៀថាពាក្យជាក់លាក់ទាំងនោះដែលនៅក្នុងសេចក្តីថ្លែងការណ៍ដែលត្រូវបានចោទប្រកាន់ គឺជាចំណុចស្នូលនៃសេចក្តីសន្និដ្ឋានរបស់ខ្លួន៖ "ជាពិសេសការប្រើពាក្យ ឃាតករ និងជាជនដៃដល់នៃអំពើប្រល័យពូជសាសន៍ (ចារី)" ដែលហាក់ដូចជាការផ្តុះបញ្ចាំងនូវទស្សនៈមួយដែលថា ជនជាប់ចោទ នួន ជា មានពិរុទ្ធភាព ទោះបីជារូបគាត់មិនទាន់ត្រូវតុលាការរកឃើញតាមផ្លូវច្បាប់ថាមានពិរុទ្ធភាពក៏ដោយ"។ *ដូចគ្នានឹងខាងលើ កន្លែងដែល* ត្រង់កថាខណ្ឌទី២៦។

នាយករដ្ឋមន្ត្រី បើសិនជាពិតមែននោះ គឺជាការបំពេញទៅតាមបទដ្ឋានស្តីពី "ការជឿដោយសមហេតុសមផល" ពីព្រោះសេចក្តីអត្ថាធិប្បាយនេះមាន "វិសមិតភាពគ្នាជាមួយនឹងគោលការណ៍ស្តីពីការសន្មតជាមុនថាមិនទាន់មានទោស" ហើយអាស្រ័យហេតុនេះ "គឺជាការប្រថុយប្រថានក្នុងការបកស្រាយថាជាការព្យាយាមក្នុងការប្រើឥទ្ធិពលដោយមិនត្រឹមត្រូវទៅលើចៅក្រម ដែលទទួលបន្ទុកលើរឿងក្តីនេះ"[36]។ សេចក្តីថ្លែងការណ៍ដោយលោកនាយករដ្ឋមន្ត្រីដែលត្រូវបានចោទប្រកាន់ គឺមានលក្ខណៈស្រដៀងគ្នាទៅនឹងសេចក្តីថ្លែងការណ៍ដែលជាលទ្ធផលនៃសាលក្រម នៅក្នុងករណីរឿងក្តីរបស់ *Ribemont* ដែលក្រុមមេធាវីការពារក្តីបានលើកយកមកអះអាង ដើម្បីគាំទ្រដល់មូលហេតុរបស់ពួកគេនៅទីនេះ ជាងមូលហេតុណាមួយក្នុងចំណោមមូលហេតុដែលមាននៅក្នុងការចោទប្រកាន់ចំពោះសេចក្តីថ្លែងការណ៍របស់លោក ហោ ណាំហុង ដែលកំពុងតែមានបញ្ហាផងដែរ។ នៅក្នុងករណីរឿងក្តីរបស់ *Ribemont* "មានមន្ត្រីជាន់ខ្ពស់មួយចំនួននៅក្នុងក្រសួងខាងនគរបាលរបស់បារាំងបានលើកឡើងចំឈ្មោះរបស់លោក Allenet de Ribemont ដោយគ្មានការលាក់លៀម និងគ្មានលក្ខណៈពិសេសណាមួយ ថាជាអ្នកញុះញង់ម្នាក់ក្នុងចំណោមអ្នកផ្សេងៗទៀត នៅក្នុងបទឃាតកម្មមួយ ដែលហេតុនេះ គាត់គឺជាជនសមគំនិតនៅក្នុងបទឃាតកម្មនោះ"[37]។ ដើម្បីឲ្យកាន់តែជាក់លាក់ជាងនេះទៀត នៅក្នុងករណីរបស់ *Ribemont* នេះ នាយកនៃនាយកដ្ឋានស៊ើបអង្កេតផ្នែកព្រហ្មទណ្ឌនៃទីក្រុងប៉ារីសដែលជាផ្នែកនៅក្នុងក្រុម"ដែលដឹកនាំការស៊ើបអង្កេតក្នុងករណីនេះ"[38] បានធ្វើសេចក្តីសង្កេតមួយថា"លោក Allenet de Ribemont [គឺជា]អ្នកញុះញង់រឿងឃាតកម្មនេះ"[39]។ សេចក្តីសង្កេតនោះត្រូវបាន "ធ្វើឡើងព្រមពេលគ្នាជាមួយនឹងកិច្ចស៊ើបសួរ [និងដែលត្រូវបាន]ធ្វើការពន្យល់ដោយសារអត្ថិភាពនៃកិច្ចស៊ើបសួរនោះ និងមានចំណងទាក់ទងគ្នាផ្ទាល់ជាមួយកិច្ចស៊ើបសួរនោះ"[40]។ ដូចគ្នា

---

[36] ឯកសារលេខ **E176/2** សេចក្តីសម្រេចលើសំណើសុំឱ្យចាត់វិធានការជាបន្ទាន់តាមវិធាន៣៥នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១១ ឧសភា ២០១២, កថាខណ្ឌទី២៩។

[37] *ករណីរឿងក្តីរបស់* Allenet de Ribemont *ទល់នឹង ប្រទេសបារាំង*, ពាក្យសុំលេខ 15175/89, សាលក្រម, តុលាការសិទ្ធិមនុស្សនៃទ្វីបអឺរ៉ុប (ECtHR), ចុះថ្ងៃទី១០ កុម្ភៈ ១៩៩៥, កថាខណ្ឌទី៤១។

[38] *ករណីរឿងក្តីរបស់* Allenet de Ribemont *ទល់នឹង ប្រទេសបារាំង*, ពាក្យសុំលេខ 15175/89, សាលក្រម, តុលាការសិទ្ធិមនុស្សនៃទ្វីបអឺរ៉ុប (ECtHR), ចុះថ្ងៃទី១០ កុម្ភៈ ១៩៩៥, កថាខណ្ឌទី៣៧។

[39] *ករណីរឿងក្តីរបស់* Allenet de Ribemont *ទល់នឹង ប្រទេសបារាំង*, ពាក្យសុំលេខ 15175/89, សាលក្រម, តុលាការសិទ្ធិមនុស្សនៃទ្វីបអឺរ៉ុប (ECtHR), ចុះថ្ងៃទី១០ កុម្ភៈ ១៩៩៥, កថាខណ្ឌទី១១។

*Case of Allenet de Ribemont v. France*, Application No. 15175/89, Judgement, ECtHR, 10 February 1995, para. 11.

[40] *ករណីរឿងក្តីរបស់* Allenet de Ribemont *ទល់នឹង ប្រទេសបារាំង*, ពាក្យសុំលេខ 15175/89, សាលក្រម, តុលាការសិទ្ធិមនុស្សនៃទ្វីបអឺរ៉ុប (ECtHR), ចុះថ្ងៃទី១០ កុម្ភៈ ១៩៩៥, កថាខណ្ឌទី១១។

នេះដែរ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ម្តងហើយម្តងទៀតថា ការរំលោភទៅលើគោលការណ៍ស្តីពីការសន្មតជាមុនថាមិនទាន់មានទោស ដែលជាលទ្ធផលបណ្តាលមកពីការធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈដោយមន្ត្រីណាម្នាក់បានកើតមានឡើងនៅពេលដែលមាន "*ការប្រកាសពីពិរុទ្ធភាពរបស់ជនជាប់ចោទ* ដោយមន្ត្រីសាធារណៈណាម្នាក់នៅមុនពេលតុលាការចេញសាលក្រម"[41]។ អាស្រ័យហេតុនេះ ការសាកល្បងនោះថាតើសេចក្តីសង្កេតរបស់មន្ត្រីណាម្នាក់នោះ "វានឹងបង្កើតបានទៅជាសេចក្តីថ្លែងការណ៍ដែលមានវិសមិតភាពជាមួយនឹងគោលការណ៍ស្តីពីការសន្មតជាមុនថាមិនទាន់មានទោសដែរ ឬទេ?"[42]។

១៥- ការធ្វើឱ្យមានភាពខុសគ្នាស្រឡះគួរឱ្យចាប់អារម្មណ៍នូវសេចក្តីថ្លែងការណ៍ ដែលត្រូវបានចោទប្រកាន់របស់ *Ribemont* និងរបស់លោកនាយករដ្ឋមន្ត្រី សេចក្តីថ្លែងរបស់លោក ហោ ណាំហុង ដែលបានចោទប្រកាន់ គឺមិនបាននិយាយយោងទៅលើជនជាប់ចោទណាម្នាក់នៅក្នុងចំណោមជនជាប់ចោទនានានោះទេ ហើយក៏មិនបានបញ្ចេញជាមតិស្តីពីពិរុទ្ធភាព*របស់នរណាម្នាក់ អំពីឧក្រិដ្ឋកម្មណាមួយ*ជាទូទៅ ឬដោយជាក់លាក់នោះដែរ។ មេធាវីការពារក្តីបានទទួលស្គាល់ថា សេចក្តីថ្លែងនោះ សូម្បីតែលើកយោងទៅលើប្រភេទនៃ "មេដឹកនាំ" ខ្មែរក្រហមក្នុងលក្ខណៈទូលំទូលាយទេ ក៏មិនបានយោងនិងបានបន្ទាបចំពោះការអះអាងដែលថា "ការលើកឡើងថាកេរ្តិ៍តំណែលរបស់ខ្មែរក្រហមមិនអាចការពារបាន យ៉ាងហោចណាស់ក៏ *បានបង្ហាញថា* មេដឹកនាំខ្មែរក្រហមមិនសមនឹងទទួលបានការការពារក្តី"[43]។ ការថ្កោលទោសទៅលើ "កេរ្តិ៍តំណែលរបស់ខ្មែរក្រហម" ដែលមានលក្ខណៈទូលំទូលាយទាំងនៅក្នុងស្រុក ក៏ដូចជា នៅអន្តរជាតិនោះ គឺមិនមានការទាក់ទងគ្នាជាមួយនឹងពិរុទ្ធភាព ឬគ្មានទោសរបស់សមាជិកដោយឡែកណាម្នាក់នៃមេដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យ ក្នុងបទឧក្រិដ្ឋកម្មណាមួយនោះឡើយ ហើយសេចក្តីថ្លែងការណ៍ដែលកំពុងជាបញ្ហា គឺទាក់ទងទាំងស្រុងជាមួយនឹងការសន្មតថាគ្មានទោសរបស់ជនជាប់ចោទនៅក្នុងសំណុំរឿងលេខ០០២ ពីបទឧក្រិដ្ឋកម្មណាមួយនោះឡើយ។

---

[41] ឯកសារលេខ **E176/2** សេចក្តីសម្រេចលើលើសំណើសុំឱ្យចាត់វិធានការណ៍ជាបន្ទាន់តាមវិធាន៣៥នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១១ ឧសភា ២០១២, កថាខណ្ឌទី១៨។ (សង្កត់ន័យបន្ថែមដោយអក្សរទ្រេត)

[42] ឯកសារលេខ **E176/2** សេចក្តីសម្រេចលើលើសំណើសុំឱ្យចាត់វិធានការណ៍ជាបន្ទាន់តាមវិធាន៣៥នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១១ ឧសភា ២០១២, កថាខណ្ឌទី២៩។

[43] ឯកសារលេខ **E219** សំណើសុំ, កំណត់សម្គាល់លេខ ១ *ខាងដើម* ត្រង់កថាខណ្ឌទី១៩។

១៦-នៅក្នុងការពិនិត្យមើលឡើងវិញលើសេចក្តីថ្លែងការណ៍របស់លោក ហោ ណាំហុង ដែលត្រូវបានចោទប្រកាន់ គឺមានភាពច្បាស់លាស់ដូចគ្នាដែរថា ផ្ទុយពីការលើកឡើងរបស់ក្រុមមេធាវីការពារក្តី គឺមិនបានលើកយោងទៅលើ"បញ្ហានានាទាក់ទងអង្គហេតុដែលជា*បញ្ហាដែលកំពុងតែស្ថិតនៅក្នុងការពិនិត្យសម្រេចរបស់តុលាការ*"ទេ[44]។ ដូចដែលអង្គជំនុំជម្រះអាចមើលឃើញយ៉ាងច្បាស់ដោយផ្ទាល់អំពីការកំណត់បទចោទលើសេចក្តីថ្លែងដែលខ្លី និងមានបំណងមិនច្បាស់របស់ក្រុមមេធាវីការពារក្តីនោះ គឺវាដាច់ចេញឆ្ងាយពី "ស្ថានភាពបង្ខិតបង្ខំ"[45] និង "ការខំព្យាយាមដោយត្រង់ៗឥតលាក់លាម និងដែលមិនអាចអនុគ្រោះឲ្យបាន ក្នុងការបញ្ចុះបញ្ចូលចៅក្រមនានានៃអង្គជំនុំជម្រះសាលាដំបូង អំពីការសម្រេចទាក់ទងនឹងអង្គហេតុនៃអត្ថបទដែលធ្វើឡើងក្រៅច្បាប់របស់លោក ហោ ណាំហុង"[46] ដែលមេធាវីការពារក្តីបានខំស្វែងរកកំណត់បទចោទក្នុងរឿងនេះ។

១៧-ថ្វីត្បិតតែ ឬប្រហែលជាដោយហេតុមកពីការខ្វះអត្ថបទសម្រាប់គាំទ្រចំពោះការអះអាង អំពីការជ្រៀតជ្រែកចូលក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការ មេធាវីការពារក្តីបានធ្វើជាសំអាងផ្សេងៗដែលមិនមានភាពរឹងមាំ ក្នុងការប៉ុនប៉ងបង្កើតនូវរូបភាពដែលជាការជ្រៀតជ្រែក។ ក្រុមមេធាវីការពារក្តីបានពោលអះអាង ដោយគ្មានអ្វីគាំទ្រ ថាសេចក្តីថ្លែងគឺមានប្រផ្នូលកាន់តែច្បាស់ថានឹងមានហេតុអាក្រក់កើតឡើងដោយសារតែមុខតំណែង "ដែលមិនអាចប៉ះពាល់បាន"របស់ ហោ ណាំហុង ដែលជារដ្ឋមន្ត្រីរបស់រាជរដ្ឋាភិបាលកម្ពុជា"[47]។ គេបានខំប្រឹងស្វែងរកការគាំទ្រចំពោះសំណើរបស់គេ ដោយឲ្យ ហោ ណាំហុង ទទួលខុសត្រូវចំពោះរាល់សកម្មភាពរបស់សមាជិកណាម្នាក់របស់រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវបានចោទប្រកាន់ ដែលទាក់ទងទៅនឹងសំណុំរឿងលេខ០០២, ០០៣ និង០០៤[48]។ ក្រុមមេធាវីការពារក្តីខំព្យាយាមទម្លាក់ទៅលើ ហោ ណាំហុង ដើម្បីធ្វើមិនឲ្យមានលទ្ធភាពរបស់ខ្លួនផ្ទាល់ ក្នុងការយកចិត្តទុកដាក់គោរពតាមការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបាន[49]។ ហើយ

---

[44] ឯកសារលេខ **E219** សំណើសុំ, កំណត់សម្គាល់លេខ ១ *ខាងដើម* ត្រង់កថាខណ្ឌទី១២។

[45] ឯកសារលេខ **E219** សំណើសុំ, កំណត់សម្គាល់លេខ ១ *ខាងដើម* ត្រង់កថាខណ្ឌទី១៤។

[46] ឯកសារលេខ **E219** សំណើសុំ, កំណត់សម្គាល់លេខ ១ *ខាងដើម* ត្រង់កថាខណ្ឌទី១៤។

[47] ឯកសារលេខ **E219** សំណើសុំ, កំណត់សម្គាល់លេខ ១ *ខាងដើម* ត្រង់កថាខណ្ឌទី១៤។

[48] ឯកសារលេខ **E219** សំណើសុំ, កំណត់សម្គាល់លេខ ១ *ខាងដើម* ត្រង់កថាខណ្ឌទី១៧។

[49] ឯកសារលេខ **E219** សំណើសុំ, កំណត់សម្គាល់លេខ ១ *ខាងដើម* ត្រង់កថាខណ្ឌទី១៤។ (" បន្ថែមពីលើនេះ កត្តាដែលដូចគ្នាទាំងនេះ ព្រមជាមួយនឹងតួនាទី "ដែលមិនអាចប៉ះពាលបាន" របស់ ហោ ណាំហុង ដែលជារដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា [*sic!*] ត្រូវតែបានគេយល់ឃើញថា ជាការប៉ុនប៉ងមួយដើម្បីជះឥទ្ធិពលមកលើអង្គជំនុំជម្រះសាលាដំបូង — ជាពិសេសភាពជាសមាជិកកម្ពុជា— ដើម្បីបន្តបំបិទមាត់មេធាវីការពារក្តីលើបញ្ហានានា ដែលរដ្ឋាភិបាលបច្ចុប្បន្នមិនពេញចិត្ត")។

ថែមទាំងបានព្យាយាមលើកឡើងថា អត្ថាធិប្បាយនេះ "ពិតជាមានផលប៉ះពាល់ទោះបីមិនមានបំណងជាក់លាក់ក៏ដោយ"[50] ដើម្បីបង្អាក់ដល់ការព្យាយាម*របស់មេធាវីការពារក្តី* ក្នុងការបន្តធ្វើការសួរដេញដោលមួយចំនួនពាក់ព័ន្ធនឹង ហោ ណាំហុង ដែលការទាមទារអាចបង្ហាញឲ្យឃើញថាគឺមិនពិត[51]។

១៨- ការលើកសំអាងរបស់ក្រុមមេធាវីការពារក្តី ដែលគាំទ្រចំពោះការពោលអះអាងអំពីការចូលជ្រៀតជ្រែកនៅក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការ គឺជាការបន្លំភ្នែក។ គេខំប្រឹងយកស្លាបព្រាស្បែកជើងជួយគាស់បញ្ចូលក្នុងសំណើសុំរបស់គេ កាលពីមុនដែលការខំព្យាយាមរបស់គេ បានត្រូវបរាជ័យក្នុងការបង្ខំឲ្យ ហោ ណាំហុង មកផ្តល់សក្ខីកម្ម[52]។ ក្រុមមេធាវីការពារក្តីក៏បានខំស្វែងរកផងដែរ ក្នុងការដាក់បញ្ចូលក្នុងបញ្ជីដែលគាំទ្រចំពោះការចោទប្រកាន់របស់ខ្លួនថា ហោ ណាំហុង ធ្លាប់បានប្តឹងទៅតុលាការ ដើម្បីឲ្យដោះស្រាយ[53]។ ការទុកចោលដោយឡែកនូវការខំព្យាយាមដើម្បីផ្តល់នូវសំណងជួសជុលដល់បុគ្គល*តាមរយៈប្រព័ន្ធតុលាការ* គឺមិនអាចចាត់ទុកថាជាការជ្រៀតជ្រែកចូលនៅក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការទេ ហើយក៏វាមិនមានតម្លៃអ្វីដែរ សូម្បីតែផ្អែកតាមការរៀបរាប់ដោយផ្ទាល់របស់ក្រុមមេធាវីក្តីក៏ដោយ ក៏បណ្តឹងទាំងនេះមិនមានជាប់ទាក់ទងនឹងសក្ខីកម្មនៅចំពោះមុខ អវតក បានកើតឡើងដោយផ្នែកខ្លះនៅក្នុងតុលាការក្រៅប្រទេស និងដែលស្ថិតក្នុងករណីមួយដែលមាន អវតក មានអត្ថិភាព។ បញ្ហាទាំងនេះមិនមានតម្លៃជាភស្តុតាងនោះទេ នៅក្នុងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការចោទប្រកាន់នេះ។

១៩- ដូចគ្នានេះដែរ ការអះអាងបន្ថែមដែលបានធ្វើឡើងនៅក្នុងសេចក្តីបន្ថែមខាងចុង គឺជាការសន្មតទៅលើសេចក្តីថ្លែងរបស់ ឯឧ. ហោ ណាំហុង ដែលគេបានលើកឡើងចោទប្រកាន់។ ដូចដែលបានពន្យល់នៅខាងលើស្រាប់ សហព្រះរាជអាជ្ញាពុំមានការជឿជាក់ទេថា សេចក្តីថ្លែងដែលគេបានលើកឡើងចោទប្រកាន់នេះ គឺមានលក្ខណៈគ្រប់គ្រាន់ដើម្បីបង្កើតបានជាមូលហេតុអាចឲ្យជឿបានមួយ ដែលថាមានការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ តាមវិធាន៣៥ នោះឡើយ។ ការណ៍នេះ

[50] ឯកសារលេខ **E219** សំណើសុំ, កំណត់សម្គាល់លេខ ១ *ខាងដើម* ត្រង់កថាខណ្ឌទី១៨។

[51] *សូមអាន ឧទាហរណ៍ដូចជា,* ប្រតិចារឹក ចុះថ្ងៃទី៩ សីហា ២០១២ ។ កថាខណ្ឌទី៧៧-៨២។ ប្រតិចារឹក ចុះថ្ងៃទី១៥ សីហា ២០១២, កថាខណ្ឌទី៣៦ -៤៨។

[52] ឯកសារលេខ **E219** សំណើសុំ, កំណត់សម្គាល់លេខ ១ *ខាងដើម* ត្រង់កថាខណ្ឌទី ៥,១៥ និង១៦។

[53] ឯកសារលេខ **E219** សំណើសុំ, កំណត់សម្គាល់លេខ ១ *ខាងដើម* ត្រង់កថាខណ្ឌទី ៤។

អនុវត្តបានទាំងសាក្សីនានាពីមុៗ និងទាំងសាក្សីនានាខាងក្រោយ។ បន្ថែមលើនេះ សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថា សេចក្ដីអត្ថាធិប្បាយរបស់ ភី ភួន ដែលគេបានចោទប្រកាន់ ពាក់ព័ន្ធនឹងការផ្ដល់សក្ខីកម្មរបស់គាត់ សូម្បីតែថាវាពិតក៏ដោយចុះ ក៏វាពុំមែនត្រូវបានធ្វើ ឡើងទៅតាមរបៀបមួយដែលមានទម្ងន់ខាងផ្លូវច្បាប់ណាមួយទៅលើសក្ខីកម្មដែលគាត់បានផ្ដល់ឲ្យ អង្គជម្រះសាលាដំបូងនោះដែរ។ ទោះជាយ៉ាងណាក៏ដោយ ក៏សហព្រះរាជអាជ្ញាធ្វើការអះអាងជាថ្មីម្ដងទៀតពីគោលការណ៍សំខាន់ៗដែលត្រូវបានការពារដោយវិធាន ៣៥ ដែលត្រូវចងចាំថា គឺជាការប្រើប្រាស់នូវអំណាចរបស់ខ្លួន*ដែលបានពិចារណាបានយ៉ាងល្អ* ដែលធ្វើជាវិភាគទានដល់ប្រសិទ្ធភាពនៃអំណាចរបស់ខ្លួន។ សហព្រះរាជអាជ្ញាធ្វើសេចក្ដីសន្និដ្ឋានថា ការលើកឡើងចោទប្រកាន់មួយនេះ មិនបានចង្អុលភ័ស្ដុតាងថាត្រូវមានចំណាត់ការបន្ថែមទៀត តាមវិធាន ៣៥ នោះឡើយ។

## IV. ដំណោះស្រាយដែលបានស្នើសុំ

អាស្រ័យហេតុដូចខាងលើនេះ មេធាវីការពារក្ដីមិនបានចង្អុលបង្ហាញភ័ស្ដុតាងគ្រប់គ្រាន់ សម្រាប់ការតវ៉ារបស់ខ្លួន ដោយផ្អែកតាមវិធាន៣៥នៃវិធានផ្ទៃក្នុងឡើយ ហើយសហព្រះរាជអាជ្ញាស្នើដោយគោរពដល់អង្គជំនុំជម្រះមេត្តាបដិសេធចោលនូវសំណើ និង សេចក្ដីបន្ថែមនេះទាំងស្រុង៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |